NON-TIMBER FOREST PRODUCTS ORGANIZATION
PRESERVING NATURAL RESOURCES EMPOWERING COMMUNITIES

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ





# របាយការណ៍ សង្ខេបប្រចាំ ឆ្នាំ ២០២១






ទូរស័ព្ទលេខ: ០៧៥ ៩៧៤ ០៣៩
ប្រអប់សំបុត្រលេខ: ៨៩០០៩
អ៊ីម៉ែល: edntfp@ntfp-cambodia.org
edntfp.cambodia@gmail.com
famntfp@ntfp-cambodia.org
អាសយដ្ឋាន:ភូមិអូរកន្ទិល,សង្កាត់បឹងកន្សែង,ក្រុងបានលុង,ខេត្តរតនគិរី

**មាតិកា**


I. **គុណតំលៃនឹងគោលការណ៍**.........................................................................................................១

II. **របាយការសង្ខេបតាមកម្មវិធីនិងសមិទ្ធិផលសម្រេចបាន**.................................................................២

២.១.កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ(NRM) ........................................................................................២

២.១.១ គម្រោងធ្វើឲ្យប្រសើរឡើងនូវសេវាអប់រំ និងការចិញ្ចឹមជីវិតសហគមន៍......................២

២.១.២ គម្រោងការលើកកំពស់ជីវភាពសហគមន៍តាមរយៈការអប់រំយូរអង្វែង.....................៤

២.២.កម្មវិធីលើកស្ទួយ និងពង្រឹងសហគមន៍ (CEA) .......................................................................១៣

២.២.១. គម្រោងការលើកកំពស់សិទ្ធិសហគមន៍ជនជាតិដើមភាគតិច.............................១៣

២.២.២. គម្រោងជំនាន់ថ្មី ......................................................................................................... ១៥

២.៣.កម្មវិធីអភិវឌ្ឍសហគមន៍និងការអប់រំ (CDE)............................................................................ ១៩

២.៣.១. គម្រោងអក្ខរកម្មអប់រំពីរភាសា......................................................................................១៩

២.៣.២. គម្រោងមជ្ឈមណ្ឌលសិក្សាសហគមន៍ចល័ត ....................................................២០

III. **របាយការណ៍សង្ខេបចំណូលចំណាយ** ............................................................................ ២២

IV. **សមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការ**NTFP.............................................................................២៤

# I. គុណតំលៃនឹងគោលការណ៍

## គុណតំលៃ

- គោរពលើកកំពស់វប្បធម៌និងប្រពៃណីជនជាតិដើមភាគតិច
- ស្រ្តីជាចលករួមចំណែកក្នុងការផ្លាស់ប្តូរសង្គម
- ធ្វើការជាក្រុមយ៉ាងសកម្មនិងស្វាហាប់
- គណនេយ្យភាពនិងតម្លាភាព

## គោលការណ៍

- ធ្វើការតាមរយៈរចនាសម្ព័ន្ធដឹកនាំបែបប្រពៃណីដែលមានលក្ខណៈបទដ្ឋានគុណភាព និងបរិមាណសម្រាប់ការចូលរួមរបស់ស្ត្រីនៅគ្រប់សកម្មភាពនិងក្នុងជួរគណៈកម្មការទាំងអស់។
- ផ្តោតសំខាន់លើវិធីសាស្រ្តបែបចូលរួមដែលសហគមន៍អាចជ្រើសរើសការអភិវឌ្ឍន៍សមស្របតាមតម្រូវការរបស់ពួកគេ។
- គាំទ្រសមាជិកសហគមន៍ដើម្បីអោយពួកគេអាចនិយាយនិងលើកឡើងពីសិទ្ធិរបស់ពួកគេ។
- គាំទ្រការប្រើប្រាស់ភាសាមូលដ្ឋាននិងលើកទឹកចិត្តបុគ្គលិកជនជាតិដើមភាគតិច។
- បញ្ជ្រាបយេនឌ័រគ្រប់ផ្នែកនិងគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង។
- ភាពជាដៃគូរជាមួយទីភ្នាក់ងាររដ្ឋាភិបាលនិងសង្គមស៊ីវិល។
- មិនរើសអើងជាតិសាសន៍ក្នុងការជ្រើសរើសបុគ្គលិក។
- រាល់ការធ្វើសេចក្តីសម្រេចចិត្តគឺអនុលោមយកគោលការណ៍ប្រជាធិបតេយ្យក្នុងការលើកកំពស់សិទ្ធិបញ្ចេញមតិរបស់បុគ្គលិកនិងអ្នកដទៃ។

## II. របាយការសង្ខេបតាមកម្មវិធីនិងសមិទ្ធិផលសម្រេចបាន

### ២.១.កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ(NRM)

### ២.១.១ ៖ គំរោងធ្វើឲ្យប្រសើរឡើងនូវការចិញ្ចឹមជីវិត និង សេវាអប់រំក្នុងសហាគមន៍(PLE)

គំរោងនេះមានភូមិគោលដៅខេត្តរតនគីរី ២១ភូមិ,៦ឃុំ,៣ស្រុក។ខេត្តស្ទឹងត្រែង ១៧ភូមិ, ៦ឃុំ,២ស្រុក។ខេត្តព្រះវិហារ ១២ភូមិ, ៦ឃុំ, ២ស្រុក។

- **ផ្នែកកសិករដាំបន្លែចំនួន១០ភូមិ៖** កសិករ១៦៨គ្រួសារទទួលបានជំនាញដាំបន្លែធម្មជាតិលក្ខណៈគ្រួសារដើម្បីឈានឈ្ពោះទៅពាក់កណ្តាលអាជីពនិងជាអាជីព។នៅបំណាច់ឆ្នាំ២០២១នេះកសិករចំនួន៦៧៧នាក់មានសួនបន្លែគំរូផ្គត់ផ្គង់អាហាររូបត្ថម្ភប្រចាំថ្ងៃក្នុងគ្រួសារនិងបង្កើតទៅជាកសិដ្ឋានចំនួន១១៩នាក់ស្រី៤២នាក់ស្មើនឹង១១៩កសិដ្ឋានហើយសំរឹតសំរាំងដំឡើងជាកសិករពាក់កណ្តាលអាជីពចំនួន១៩នាក់/ស្រី១០នាក់។កសិករបង្កើនប្រាក់ចំណូលដល់កសិករដែលនាំទៅរកអាហាររូបត្ថម្ភកាន់តែប្រសើរក្នុងគ្រួសារក្នុងនោះកសិករបានចំណូល៥០០$ឡើងពីការលក់បន្លែនិងចិញ្ចឹមសត្វចំនួន១៧នាក់ស្រី១០នាក់ធៀបជាមួយផែនការរំពឹងទុកចំនួន៦៥នាក់បញ្ជាក់ថាទាបជាងផែនការ៧៩%ដោយសារខ្វះប្រភពទឹកស្រោចស្រពពួកសិករត្រូវចំណាយទុនធំដើម្បីដោះស្រាយប្រភពទឹក។កសិករក្នុងវ័យមានកម្លាំងផលិតត្រូវបោះបង់ការផលិតហើយចំណាកស្រុកទៅស៊ីឈ្នួលលក់កម្លាំងពលកម្មអោយក្រុមហ៊ុនឬអ្នកមានទុនវិនិយោគធំៗដូចជាចំការចេកចំការចន្ទីចម្ការដំឡូង ។
- **ផ្នែកអភិវឌ្ឍន៍ធនធានយុវជនសហាគមន៍១០ភូមិ៖** តម្រូវការនិងយុទ្ធសាស្ត្ររបស់សហាគមន៍ត្រូវបានកំណត់ដោយការចូលរួមដោយសមាជិកសហាគមន៍ជាពិសេសស្ត្រី កុមារី និងអ្នកពិការភាពដើម្បីប្រមូលការយល់ឃើញនិងធនធាននៅក្នុងសហាគមន៍ដើម្បីដោះស្រាយបញ្ហា។សហាគមន៍ចំនួន៩ភូមិបានលើកផែនការដែលជាតម្រូវការនិងផែនការយុទ្ធសាស្ត្ររបស់ខ្លួនតាមរយៈការសម្របសម្រួលដោយយុវជនក្នុងការប្រមូលផ្តុំនិងដឹកនាំសហាគមន៍ដើម្បីតាមដានការផ្លាស់ប្តូរនៅក្នុងសហាគមន៍។ ធៀបជាមួយផែនការរំពឹងទុកចំនួន៨ភូមិ។ចំនួនភូមិនៃភូមិដែលបានអនុវត្តផែនការគម្រោងរបស់ពួកគេមានចំនួន៦ភូមិធៀបជាមួយផែនការរំពឹងទុកចំនួន៦ភូមិ។អភិវឌ្ឍសមត្ថភាពសមាជិកយុវជនក្នុងសហាគមន៍ដើម្បីធ្វើការស្រាវជ្រាវសកម្មភាពចូលរួម (PAR) ដើម្បីវិភាគបញ្ហាសង្គម សេដ្ឋកិច្ច និងបរិស្ថាន។

  ក). យុវជនដែលមានជំនាញPARក្នុងខេត្តរតនគិរីចំនួន៦នាក់ស្រី៥នាក់ខេត្តស្ទឹងត្រែងចំនួន៨នាក់ស្រី ៦ នាក់ និងខេត្តព្រះវិហាចំនួន៤នាក់ស្រី ២ នាក់។ សរុបចំនួន១៧នាក់ស្រី ១២ នាក់ ធៀបជាមួយសូចនាករំពឹងទុកចំនួន១៦នាក់។

ខ). យុវជនដែលបានចូលរួមពេញលេញក្នុងវគ្គបណ្តុះបណ្តាលPARក្នុងខេត្តរតនគិរីចំនួន ៦នាក់ស្រី៥នាក់ខេត្តស្ទឹងត្រែងចំនួន១២នាក់ស្រី៨នាក់និងខេត្តព្រះវិហារចំនួន៤នាក់ស្រី ២ នាក់។សរុបចំនួន២០នាក់ស្រី១៥នាក់ ធៀបជាមួយសូចនាកររំពឹងទុកចំនួន១៨នាក់។

គ). យុវជនដែលមានសមត្ថភាព បានអនុវត្ត PAR នៅក្នុងសហគមន៍របស់ពួកគេក្នុងខេត្តរតនគិរីចំនួន៥នាក់ស្រី៤ នាក់ ខេត្តស្ទឹងត្រែងចំនួន៦នាក់ស្រី ៦ នាក់ និងខេត្តព្រះវិហារចំនួន៤នាក់ស្រី ២ នាក់ ។ សរុប ១៥នាក់ស្រី១២នាក់ ធៀបជាមួយសូចនាកររំពឹងទុកចំនួន១២នាក់។

- **ផ្នែកអប់រំនិងសិទ្ធិកុមារចំនួន៦សាលាបឋមសិក្សា៖** គណកម្មការទ្រទ្រង់សាលានិងក្រុមប្រឹក្សាកុមារនៅក្នុងសាលាបឋមសិក្សាចំនួន១២ត្រូវបានគាំទ្រពីគំរោងក្នុងដំណើរការពង្រឹងកិច្ចប្រជុំប្រចាំត្រីមាស៖ កុមារនៅក្នុងសហគមន៍គោលដៅទទួលបានការអប់រំតាមរយៈគ្រូបង្រៀន និងបុគ្គលិកអប់រំបានបំពេញតួនាទីរបស់ពួកគេបានយ៉ាងល្អ។ សាលាបឋមសិក្សាចំនួន៩ត្រូវបានអនុវត្ត៥០%នៃបញ្ជីត្រួតពិនិត្យផ្លូវការនៃគោលការណ៍សាលាបរិស្ថានល្អរបស់ក្រសួងអប់រំ យុវជន និងកីឡា ធៀបជាមួយសូចនាកររំពឹងទុកចំនួន៣សាលា។ក្រុមប្រឹក្សាសិស្ស/ក្លឹបកុមារ និង SSC នៅសាលាបឋមសិក្សាគោលដៅត្រូវបានអនុវត្ត និងដំណើរការក្នុងគោលបំណងលើកកម្ពស់អនុវត្តបញ្ជីត្រួតពិនិត្យរបស់សាលាបរិស្ថានល្អ។

កិច្ចប្រជុំ/ព្រឹត្តិការណ៍បានធ្វើឡើងដោយក្រុមប្រឹក្សាសិស្ស/ក្លឹបកុមារ និងគណកម្មការទ្រទ្រង់សាលាដើម្បីផ្សព្វផ្សាយបញ្ជីត្រួតពិនិត្យសាលារៀនបរិស្ថានល្អ ខេត្តរតនគិរី១២ប្រជុំអ្នកចូលរួម៦៧ស្រី៣០នាក់, ខេត្តព្រះវិហា ៣០ប្រជុំអ្នកចូលរួម ៤៩១នាក់ស្រី២៤០នាក់, ខេត្តស្ទឹងត្រែង១៤ប្រជុំ អ្នកចូលរួម ២២៤នាក់ស្រី ១១៣។ សរុបទាំង៣ខេត្ត១២សាលាបានប្រជុំប្រចាំត្រីមាសចំនួន ៥៦ប្រជុំ ធៀបជាមួយសូចនាកររំពឹងទុកចំនួន៧២ប្រជុំ ទាបជាងផែនការ២២%ដោយសាសាលានៅខេត្តរតនគិរីនិងខេត្តស្ទឹងត្រែងមានការរឹតបន្តឹងមិនអនុញ្ញាតបើកសាលាដោយបញ្ហាកូវីត។សមាជិកក្រុមប្រឹក្សាសិស្ស/ក្លឹបកុមារ និង គណកម្មការទ្រទ្រង់សាលាចំនួន៥៤៨នាក់ស្រី២៧០នាក់បានចូលរួមក្នុងកិច្ចប្រជុំ ឬព្រឹត្តិការណ៍នានា។ គិតជាមធ្យមស្មើ១៣នាក់ក្នុង១សាលាដូច្នេះ១២សាលាស្មើ១៥៦នាក់ ធៀបជាមួយសូចនាកររំពឹងទុកចំនួន១៦៨នាក់ ។

## ២.១.២ ៖ គម្រោងការលើកកំពស់ជីវភាពសហគមន៍តាមរយៈការអប់រំយូរអង្វែង

**Act. 1.1.1 និង1.1.2: ដំណើរការជ្រើសរើសក្រុមកសិករ និងប្រមូលពត៌មានបឋម:**

▪ ប្រជុំជ្រើសរើសក្រុមកសិករ នៅភូមិសំបូរ ឃុំសង្កែរពីរ បានចំនួន ២៥នាក់ ស្រី២១នាក់ (ចិញ្ចឹមមាន់ចំនួន ១៨នាក់ ស្រី១៦នាក់ ដាំបន្លែចំនួន៧នាក់ ស្រី៥នាក់)។ជ្រើសរើសក្រុមកសិករនៅភូមិជោគជ័យបានចំនួន១១នាក់ ស្រី៧នាក់(ចិញ្ចឹមមាន់ចំនួន៨នាក់ ស្រី៦នាក់ និងដាំបន្លែចំនួន៣នាក់ ស្រី១នាក់)។


Picture 1: ការផ្តល់បច្ចេកទេសពីការធ្វើជីកំប៉ុស្ត និងថ្នាំធម្មជាតិ

**Act.1.1.3: ការផ្តល់បច្ចេកទេសដាំបន្លែដល់ក្រុមកសិករ**

ការផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសដល់ក្រុមកសិករ នៅភូមិសំបូរ និងភូមិជោគជ័យ ឃុំសង្កែរពីរ ស្រុកឆែប បានចំនួន៥វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន៣៣នាក់ ស្រី២៦នាក់។

- ចិញ្ចឹមមាន់មានចំនួន២៦នាក់ ស្រី២២នាក់
- ដាំបន្លែមានចំនួន៧នាក់ ស្រី៤ នាក់។

**Act.1.1.4: ការប្រជុំត្រីមាស(COP)ជាមួយក្រុមកសិករ និងវិស័យឯកជន**


Picture 2: សកម្មភាព COP

ប្រជុំត្រីមាសក្រុមកសិករ(COP) ៣លើក (ថ្នាក់ភូមិ១លើក និងថ្នាក់ស្រុក២លើក)។ថ្នាក់ភូមិ ប្រជុំកសិករភូមិសំបូរ និងភូមិជោគជ័យ មានអ្នកចូលរួមសរុបចំនួន៣៦នាក់ ស្រី២៧នាក់ (ចិញ្ចឹមមាន់មានចំនួន២៧នាក់ ស្រី២២នាក់ និងដាំបន្លែមានចំនួន៩នាក់ ស្រី៥នាក់។

កសិករឈ្មោះ អ៊ុំ សំអុល ដែលអនុវត្តបានជោគជ័យ ទាក់ទងបញ្ហាសត្វល្អិតប្រភេទចៃស ដែលបំផ្លាញលើដំណាំសណ្តែកគួរ និងត្រសក់ដោយប្រើសាប៊ូលាងចាន១ស្លាបព្រាបាយ ប្រេងសណ្តែក១ស្លាបព្រាបាយ ទឹកស្អាត២លីត្រ លាយចូលគ្នា រួចកូរវាអោយសប់ ហើយយកទៅបាញ់កន្លែង ដែលមានសត្វចៃសលើដំណាំសណ្តែកគួរនិងត្រសក់បញ្ជាក់ បាញ់ពេលព្រឹកនិងពេលល្ងាចបាញ់១ម្តងក្នុងមួយថ្ងៃ។

- ថ្នាក់ស្រុក មានកសិករគោលដៅទាំង៨ភូមិ(ភូមិព្រាល,សន្លុងជ័យ,បឹង,អូរ,ទន្លាប់,ឫស្សីស្រុបូរ និងជោគជ័យ) ដែលមានអ្នកចូលរួមសរុបចំនួន២៣នាក់ ស្រី១២នាក់។កសិករបានចែករំលែកពីបញ្ហាដែលជួបប្រទះទាំងចិញ្ចឹមមាន់ និងដាំបន្លែ និងចែករំលែកពីបទពិសោធន៍ដែលទទួលបានជោគជ័យ។

Act.1.1.5: ទស្សនៈកិច្ចសិក្សារបស់ក្រុមកសិករ N/A

**Act.1.1.6: ការផ្សព្វផ្សាយពីការបម្រែបំរួលអាកាសធាតុដល់ក្រុមកសិករ**

កសិករចូលរួមការបញ្ញាបពីបម្រែបម្រួលអាកាសធាតុសរុបចំនួន៣៦នាក់ ស្រី២៧នាក់ (ចិញ្ចឹមមាន់មានចំនួន២៧នាក់ ស្រី២២នាក់ និងដាំបន្លែមានចំនួន៩នាក់ ស្រី៥នាក់។ កសិករភូមិសំបូរចំនួន២៦ ស្រី២២នាក់,កសិករ ភូមិជោគជ័យ១០នាក់ស្រី៥នាក់, ពួកគេទទួលការផ្សព្វ ផ្សាយនិងយល់ដឹងអំពីការបម្រែបម្រួលអាកាសធាតុ និងមូលហេតុបណ្តាលឲ្យមានការបម្រែបម្រួលអាកាសធាតុ។កសិករបានយល់ដឹង៧៥%នៃចំនួនអ្នកចូលរួមសរុប តាមរយៈការសួរសំនួរ ចម្លើយ និងការលើកដៃ។

**Act.1.1.7: ការសម្របសម្រួលស្វែងរកការគាំទ្របច្ចេកទេសពីមន្ទីរកសិកម្ម**



Picture 3: ការគាំទ្របច្ចេកពីមន្ត្រីកសិកម្មស្រុកឆែប

បានសហការជាមួយមន្ត្រីកសិកម្មស្រុកឆែបផ្តល់ប្រឹក្សាបច្ចេកទេសដល់ក្រុមកសិករចិញ្ចឹមមាន់ និងដាំបន្លែ ចំនួន២លើក នៅភូមិសំបូរ និងភូមិជោគជ័យ ដែលមានអ្នកចូលរួមសរុបចំនួន៣៨នាក់ ស្រី២០នាក់។

- ភូមិសំបូរចំនួន១៨នាក់ ស្រី១៧នាក់(ចិញ្ចឹមមាន់ចំនួន១២នាក់ ស្រី១១នាក់ និងដាំបន្លែចំនួន៦នាក់ ស្រី៦នាក់)
- ភូមិជោគជ័យចំនួន៨នាក់ ស្រី៣នាក់ (ចិញ្ចឹមមាន់ចំនួន៥នាក់ ស្រី៣នាក់ និងដាំបន្លែចំនួន២នាក់ ស្រី០)។

កសិករបានយល់ដឹង៨៥%នៃចំនួនអ្នកចូលរួមសរុប៣៨នាក់ តាមរយៈការសង្កេត សួរសំណួរ និងអនុវត្តជាក់ស្តែង។



Picture 4 ការគាំគ្រាប់ពូជ និងសម្ភារៈ

**Act.1.2.1: ការផ្តល់គ្រាប់ពូជ និងសម្ភារៈកសិកម្មដល់ក្រុមកសិករ**

គាំទ្រគ្រាប់ពូជបន្លែដល់ក្រុមកសិករ ចំនួន ១១នាក់ ស្រី៥នាក់ ក្នុងនោះភូមិសំបូរចំនួន៧នាក់ ស្រី៥នាក់ និងភូមិជោគជ័យចំនួន៥នាក់ស្រី០នាក់ជាកសិករដែលបានដាំបន្លែ។សម្រាប់គ្រាប់ពូជដែលក្រុមកសិករទទួលបានមានដូចជាសណ្តែកគួរ១០០ក្រាម ស្ពៃចង្កឹះ១០០ក្រាម ត្រប់វែង១កញ្ចប់ននោង១កញ្ចប់។តើបានភ្ជាប់កសិករប៉ុន្មាន៣៦នាក់ជា មួយក្រុមហ៊ុនលក់ពូជន៍និងសម្ភារៈកសិកម្ម។

**Act.1.2.2 &1.2.3: ការភ្ជាប់ក្រុមកសិករ ទៅនឹងវិស័យឯកជន N/A**

**Act.1.2.4: ការធ្វើចំការបង្ហាញ**



Picture 5 : ការធ្វើចំការបង្ហាញ

កសិដ្ឋានកសិករគំរូដាំបន្លែ ពាក់កណ្តាលអាជីព ត្រូវបានរៀបចំចំនួន៥គ្រួសារ ក្នុងនោះមានកសិករឆ្នាំ២០១៩មាន១គ្រួសារ, ២០២០មាន២គ្រួសារ និង២០២១មាន២គ្រួសារ។

កសិដ្ឋានកសិករគំរូពាក់ កណ្តាលអាជីពចំនួន៥ ត្រូវបាន រៀបចំឡើង ។ ទី១ឈ្មោះ ផាវ យ៉ន ភេទប្រុស មានផ្ទៃដី ៣៥០ម៉ែតការេ នៅភូមិសំបូរ ឃុំសង្កែរពីរ ស្រុកឆែប ខេត្តព្រះវិហារ។ ទី២ឈ្មោះយឹម ច្រិប ភេទស្រី មានផ្ទៃដី ៣២៣ម៉ែតការេ នៅភូមិសន្លុងជ័យ ឃុំរក្សា ស្រុករវៀង ខេត្តព្រះវិហារ។ទី៣ឈ្មោះ គិម សារឿន ភេទស្រី មានផ្ទៃដី ៤៩០ម៉ែតការេនៅភូមិទន្លាប់ ឃុំរួសរាន់ ស្រុករវៀង ខេត្តព្រះវិហារ។ ទី៤ ឈ្មោះ ម៉ៅ មាន ភេទប្រុស មានផ្ទៃដី៩០០$m^2$ នៅភូមិជោគជ័យ ឃុំសង្កែរពីរ ស្រុកឆែប ខេត្តព្រះវិហារ។ ទី៥ ឈ្មោះ ខូវ សុខលីន ភេទប្រុស មានផ្ទៃដីចំនួន៥០០$m^2$ នៅភូមិទន្លាប់ ឃុំរួសរាន់ ស្រុករវៀង ខេត្តព្រះវិហារ។

**Act.1.2.5 & 1.2.6: ការពង្រឹងបច្ចេកទេសដល់ក្រុមកសិករ**

**Act.1.2.7: ការជ្រើសរើសកសិករពាក់កណ្តាលអាជីព**



Picture 6:ការជ្រើសរើសកសិករពាក់កណ្តាលអាជីព

កសិករពាក់កណ្តាលអាជីព ជ្រើសរើសបាន ចំនួន៧គ្រួសារ ដែលមាននៅភូមិសំបូរ ចំនួន៥នាក់ ស្រី៤នាក់ និងភូមិសំបូរបានចំនួន២នាក់ ស្រី០។ ការជ្រើសរើសនេះបាន គិតទៅលើការដាំរយៈពេលមួយឆ្នាំពេញ ដាំច្រើនដង ។

**Act.1.2.8: ការភ្ជាប់ក្រុមកសិករ ទៅ នឹងវិស័យឯកជន N/A**

**Act.1.2.9: កសិករសំខាន់ៗបានចូលរួមខ្សែសង្វាក់ផលិតកម្ម**

- ទីប្រឹក្សាបច្ចេកទេសត្រូវបានជ្រើសរើសនិងចុះកិច្ចព្រមព្រៀងអនុវត្តការបណ្តុះបណ្តាលរោងសាកល្បងជាមួយកសិករ១៥នាក់នៅភូមិទន្លាប់ ឃុំរួសរាន់ ស្រុករវៀង ខេត្តព្រះវិហា។



Picture 7:វគ្គបណ្តុះបណ្តាលពីខ្សែសង្វាក់ផលិតកម្ម

បានផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករចំនួន១៥នាក់ ស្រី១២នាក់ បានចំនួន៥វគ្គ ស្មើនឹង ៨ប្រធាន បទ (ទី១. ការគ្រប់គ្រងសួន លក្ខណៈគ្រួសារ, ទី២.ការអនុវត្តកសិកម្មល្អ,

ទី៣.ប្រតិទិនដាំដុះ និងទីផ្សារ, ទី៤.ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង, ទី៥.សុវត្ថិភាពចំណីអាហារ និងការទុកដាក់ បន្លែក្រោយពេល ប្រមូលផល, ទី៦. គាំទ្រក្រុមកសិករភ្ជាប់ ជាមួយអ្នកលក់ បន្លែ បោះដុំ/រាយនៅផ្សាររវៀង, ទី៧. ចុះកិច្ចសន្យា កសិកម្ម (ផ្គត់ផ្គង់ និងទិញលក់) រវាងតំណាង ក្រុម កសិករនិងអ្នកលក់នៅផ្សារ, ទី៨. ចុះតាមដានសួនបន្លែកសិករ ដើម្បីផ្តល់បច្ចេកទេសបន្ថែម)។

**Act.1.2.11: ការជីកអណ្តូង N/A**

**Act. 2.1.1: ដំណើរការជ្រើសរើសក្រុមយុជន**



Picture 8:ដំណើរការជ្រើសរើសក្រុមយុវជន

យុវជនPARត្រូវបានជ្រើសរើសចំនួន ៤នាក់ស្រី២នាក់ ២ភូមិ(ភូមិសំបូរ ចំនួន២នាក់ ស្រី១ និងភូមិជោគជ័យចំនួន២នាក់ ស្រី១នាក់)ជ្រើសរើសក្រុមយុវជនSKYEនៅភូមិទន្លាប់ ឃុំរូសរ៉ាន់ ស្រុករវៀង ជ្រើសរើសយុវជនបានចំនួន១៨នាក់ ស្រី១០នាក់ និងឫស្សីស្រុកបានចំនួន១៦នាក់ ស្រី១០នាក់។

**Act. 2.1.2: ការផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមយុវជន PAR**



Picture 9: បណ្តុះបណ្តាលក្រុមយុវជន ពីជំនាញ PAR

យុវជនចំនួន៦នាក់ ស្រី២នាក់ បានទទួលវគ្គបណ្តុះបណ្តាល ស្តីពីការសិក្សា ស្រាវជ្រាវតាមបែបចូលរួមដើម្បីធ្វើសកម្មភាព(PAR) ដែលមកពីភូមិសំបូរ ភូមិជោគជ័យ ភូមិទន្លាប់ និងភូមិឫស្សីស្រុក។**លទ្ធផល៖** យុវជនបាន ដឹងពីនិយមន័យPAR គោលការណ៍របស់PAR ជំហាន ទាំង៦របស់PAR ចេះប្រើសំណួរដើម្បីសួរទៅសហគមន៍ ដោយប្រើសំណួរសង្កេត សំណួរត្រិះរិះពិចារណា និងសំណួរពីស្ថានភាពទូទៅ ដែលបាន យល់ដឹង៧០%នៃចំនួនអ្នកចូលរួមសរុប៦នាក់ តាមរយៈការសួរសំណួរ ការចែកក្រុមពិភាក្សា និងការអនុវត្តជាក់ស្តែកនៅក្នុងមូលដ្ឋាន។

**Act 2.1.4: ការផ្តល់វគ្គបណ្តុះបណ្តាលដលក្រុមយុវជនពីការកសាងគម្រោង និងរៀបចំក្រុមយុវជន N/A**



Picture 10: ការចុះកិច្ចព្រមព្រៀងរវាងក្រុមយុវជន និងNTFP នៅឃុំរូសរាន់

**Act 2.1.5 និង 2.1.6: N/A**

**Act 2.1.7: ក្រុមយុវជនអនុវត្តផែនការសហគមន៍**

. ការរៀបចំចុះកិច្ចព្រមព្រៀងលើគម្រោងសំណើរ របស់ យុវជន មានអ្នកចូលរួមចំនួន១០នាក់ ស្រី២នាក់។ គម្រោង យុវជន នៅភូមិ ឫស្សីស្រុក ធ្វើលើការសាង សង់បង្គន់ អនាម័យ ដែលមាន ការ

គាំទ្រថវិកាពីNTFP ចំនួន400$ និងបដិភាគពីសហគមន៍ចំនួន5250$ ។ គម្រោងយុវជននៅភូមិទន្លាប់ធ្វើទៅលើការសាងសង់បង្គន់អនាម័យ ដែលមានការគាំទ្រពីNTFP ចំនួន 400$ និងចូលរួមបដិភាគ ពីសហគមន៍ ចំនួន6000$ ។

**Act 2.1.8: ការអភិវឌ្ឍន៍សមត្ថភាពក្រុមយុវជន លើការគ្រប់គ្រងគម្រោង**



Picture 11: ការបណ្តុះបណ្តាលក្រុមយុវជន ពីការកសាង និងគ្រប់គ្រងគម្រោង

បានផ្តល់ វគ្គបណ្តុះបណ្តាលស្តីពីការកសាងគម្រោង និងការគ្រប់គ្រងគម្រោងដល់យុវជនសរុបចំនួន៨នាក់ ស្រី៤នាក់ មកពីភូមិបឹងចំនួន២នាក់ ស្រី០នាក់ ភូមិសន្លុងជ័យចំនួន២នាក់ ស្រី២ ភូមិទន្លាប់ចំនួន២នាក់ ស្រី១ និងភូមិឬស្សីស្រុកចំនួន២នាក់ ស្រី១ រយៈពេល២ថ្ងៃ ដែលមានប្រធានបទដូចជា៖ សិក្សាវដ្តនៃគម្រោង, ដើមឈើបញ្ហា, ក្របខណ្ឌលទ្ធផល, ផែនការសកម្មភាព, ការត្រួតពិនិត្យ, របាយការណ៍។

**Act.2.2.13: ការបោះជំរុំរបស់ក្រុមយុវជន N/A**

**Act.2.2.16 & 2.2.17:ការផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមយុវជន**



Picture 12: ការបណ្តុះបណ្តាលក្រុមយុវជន SKYE

យុវជនបានរៀបចំបង្កើតរចនា សម្ព័ន្ធក្នុងក្លឹបយុវជន ដែលមាននៅភូមិទន្លាប់ និងភូមិឬស្សីស្រុក ដែលមានអ្នកដឹកនាំក្លឹបSKYE ចំនួន៤នាក់ ក្នុងមួយក្លឹប។យុវជនដឹកនាំសម្របសម្រួលមេរៀនSKYE នៅភូមិទន្លាប់ ដែលមានសមាជិកចំនួន១៨នាក់ ស្រី១០នាក់ និងភូមិ ឬស្សីស្រុក មានសមាជិកចំនួន១៦នាក់ ស្រី១០នាក់។ ភូមិឬស្សីស្រុក បានសម្របសម្រួលមេរៀនSKYEក្នុងប្រធានបទទី១ដល់ទី៦ ភូមិទន្លាប់ បានសម្របសម្រួល មេរៀនSKYE ក្នុងប្រធានបទទី១ដល់ទី៦។

Act.3.1.1 & 3.1.2: **ដំណើរការជ្រើសរើសសាលា និងផ្សព្វផ្សាយពីសិទ្ធិកុមារនិងបរិស្ថាន** N/A

Act.3.1.3:**ផ្សព្វផ្សាយពីអាហារូបត្ថម្ភ** N/A

**Act.3.1.5: ប្រជុំត្រីមាសជាមួយគណៈកម្មការទ្រទ្រង់សាលា**



Picture 13: ការប្រជុំត្រីមាសគណៈកម្មការទ្រទ្រង់សាលា

- គាំទ្រការប្រជុំត្រីមាសរបស់គណកម្មការទ្រទ្រង់សាលាទាំង៤សាលា (មានសាលាបឋមសិក្សាព្រាល, សាលាបឋមសិក្សាអូរ, សាលាបឋមសិក្សាទន្លាប់ និងសាលាបឋមសិក្សាឬស្សីស្រុក) ដែលបានប្រជុំគ្រប់៤ត្រីមាស ទាំង៤

សាលា ដែលមានអ្នកចូលរួមសរុប២៣៩នាក់ ស្រី១១៨នាក់។

**លទ្ធផល**

- សាលាបង្ហាញពីសមិទ្ធិផលដែលទទួលបានពីNTFP និងសកម្មភាពដែលសម្រេចបានក្នុងឆ្នាំ២០២១
- សិស្សបោះបង់ទាំង៤សាលា មានចំនួន១៣នាក់ ស្រី៦នាក់ ក្នុងនោះភាគច្រើនជាសិស្សថ្នាក់ទី១ ដែលបានទៅចំការស្រែជាមួយឪពុកម្តាយ
- សិស្សពិការទាំង៤សាលាមានចំនួន៦នាក់ ស្រី៤នាក់ (ពិការភ្នែក មើលមិនសូវច្បាស់ និងនិយាយមិនសូវច្បាស់)
- សិស្សចេះអានតាមកម្រិតថ្នាក់មានដូចជា៖ សាលាបឋមសិក្សាព្រាល ៦០% នៃសិស្សសរុបចំនួន៨៥នាក់។សាលាឬស្សីស្រុក ៦០% នៃចំនួនសិស្សសរុបចំនួន៩១នាក់។សាលាបឋមសិក្សាទន្លាប់ ៥៦% នៃសិស្សសរុបចំនួន៩២នាក់។សាលាបឋមសិក្សាអូរ ៦០% នៃសិស្សសរុបចំនួន៩៧នាក់។

**Act.3.1.6: ប្រជុំត្រីមាសជាមួយក្រុមប្រឹក្សាកុមារ**



Picture 14: ការប្រជុំត្រីមាសក្រុមប្រឹក្សាកុមារ

▪ គាំទ្រការប្រជុំត្រីមាស ក្រុមប្រឹក្សាកុមារ ទាំង៤សាលា អ្នកចូលរួមសរុបចំនួន២០២នាក់ ស្រី១២២នាក់។

**លទ្ធផល**

- លោកនាយកបាន បង្ហាញពី សកម្មភាព របស់ ក្រុមប្រឹក្សាកុមារ ដែលបាន ដើរតួរ ជា អ្នកចែក កិច្ចការសាលាដល់សិស្ស ដែលមិនបាន មក ទទួល និង ប្រមូលកិច្ចកសាលាឲ្យគ្រូ និងបានជួយជម្រុញកុមារណាដែលមិនបាន យក កិច្ចការឬ មិនបានធ្វើកិច្ចការឲ្យគ្រូ។
- កុមារបានលើកសំណើសុំសម្ភារៈសម្រាប់លម្អថ្នាក់រៀន សម្រាប់ឆ្នាំសិក្សាថ្មីខាងមុខនេះ។
- កុមារបានលើកពីបញ្ហាប្រឈមក្នុងការអនុវត្តតួនាទីរបស់ខ្លួន គឺកុមារមួយចំនួនមិនស្តាប់តាមការណែនាំរបស់ក្រុមប្រឹក្សាកុមារ។

**Act.3.1.7: ការទិញ សម្ភារៈ និងដាំកូនឈើ នៅក្នុងសាលា**

▪ សាលាបឋមសិក្សាចំនួន៣បានទទួលសម្ភារៈពីគំរោង រួមមាន៖

- សាលាបឋមសិក្សាអូរ ទទួលបានទោងយោលចំនួន១ និងទោងរំអិលចំនួន១។



- សាលាបឋមសិក្សាឬស្សីស្រុកទទួលបានទោងរំអិលចំនួន១ និងទោងរំអិលចំនួន១។
- សាលាបឋមសិក្សាទន្លាប់ទទួលបានទោងរំអិលចំនួន១ និងទោងយោលចំនួន១។

Picture 15: ការផ្តល់សម្ភារៈដល់សាលា

## Act 3.1.8: ការធ្វើអធិការកិច្ចពីមន្រ្តីការិយាល័យអប់រំស្រុក



Picture 16: ការិយាល័យអប់រំចុះពិនិត្យមើលការរៀន និងបង្រៀន

គាំទ្រមន្ត្រីការិយាល័យអប់រំស្រុករវៀង និងប្រធានកម្រង ចូលរួមប្រជុំគណកម្មការទ្រទ្រង់សាលា ទាំង៤ ដែលមានមន្ត្រីការិយាល័យអប់រំស្រុករវៀង ចំនួន១នាក់ ស្រី០ និងប្រធានកម្រងតាមសាលាទាំង៤។**លទ្ធផល** មន្ត្រីការិយាល័យអប់រំស្រុករវៀង និងប្រធានគម្រោង តាមសាលានីមួយៗបាន ពង្រឹងពីតួនាទីគណកម្មការទ្រទ្រង់សាលា សកម្មភាពរបស់គណកម្មការ និងការរៀបចំគណកម្មការថ្នាក់រៀនដែលមាននៅក្នុងថ្នាក់ទី១ ដល់ថ្នាក់ទី៦។ ក្នុងនោះ មន្ត្រីការិយាល័យអប់រំស្រុក បានបង្ហាញពីរបៀបនៃការរៀននិងបង្រៀនតាមប្រព័ន្ធOnline និងមានការចែកជូន ហាតឌីស តាមសាលានីមួយៗ សម្រាប់ចាក់បង្ហាញដល់សិស្សានុសិស្សដែលមានជាវីឌីអូរបង្រៀនស្រាប់ និងបានប្រាប់ពីការចែកសៀវភៅដល់សិស្សថ្នាក់ទី១ និងទី២

សម្រាប់ជំនួយអាណាព្យាបាលក្នុងការបង្រៀនកូននៅផ្ទះ ដែលក្នុងមួយនាក់ទទួលបានចំនួន៧គីឡូក្រាម។

## Act.3.1.9: ទិវាសិទ្ធិកុមារ និងបរិស្ថាន

- ផ្សព្វផ្សាយពីបរិស្ថាន និងទិវាសម្អាតបរិស្ថានក្នុងភូមិ ធ្វើបានចំនួន៥ភូមិរួមមានៈ
  - ភូមិសន្លុងជ័យ ឃុំរក្សា មានអ្នកចូលរួមចំនួន១៩នាក់ ស្រី១៣នាក់។
  - ភូមិព្រាល ឃុំរក្សា មានអ្នកចូលរួមចំនួន៣១នាក់ ស្រី១៥នាក់។
  - ភូមិបឹង ឃុំបៀប មានអ្នកចូលរួមចំនួន ២៧នាក់ ស្រី១៧នាក់។
  - ភូមិឬស្សីស្រុក ឃុំរួសរាន់ មានអ្នកចូលរួមសរុបចំនួន ៣០នាក់ ស្រី១៨នាក់ ។

- ភូមិទន្លាប់ ឃុំរូសរាន់មានអ្នកចូលរួមចំនួន៣៨នាក់ ស្រី១៧នាក់។

អ្នកចូលរួមសរុបទាំងអស់ចំនួន ១៩៥នាក់ ស្រី៨០នាក់។



Picture 17: ទិវាសិទ្ធិកុមារ

▪ ប្រជុំផ្សព្វផ្សាយពីសិទ្ធិកុមារ និងការអប់រំកូនតាមបែបវិជ្ជមានបានចំនួន៥ភូមិ

- ភូមិទន្លាប់ មានអ្នកចូលរួមចំនួន៣៥នាក់ ស្រី១៩នាក់។
- ភូមិឬស្សីស្រុក មានអ្នកចូលរួមចំនួន៥១នាក់ ស្រី២១នាក់។
- ភូមិព្រាល មានអ្នកចូលរួមចំនួន៥៩នាក់ ស្រី៣៦នាក់ ។
- ភូមិបឹង មានអ្នកចូលរួមចំនួន៥០នាក់ ស្រី២៩នាក់។
- ភូមិអូរ មានអ្នកចូលរួមចំនួន៣៣នាក់ ស្រី១៩នាក់។

## Act.3.1.10: ការគាំទ្រសម្ភារៈសម្រាប់សាលា

គាំទ្រសម្ភារៈដល់សាលាទាំង៤ រួមមាន៖



Picture 18: ការសាងសង់បង្គន់អនាម័យក្នុងសាលា

▪ សាលាបឋមសិក្សាព្រាល ទទួលបានសម្ភារៈសាងសង់បង្គន់អនាម័យ ចំនួន១ខ្នង ២បន្ទប់ ដែលមានខាងNTFP ផ្តល់ការគាំទ្រសម្ភារៈចំណាយអស់ចំនួន642 $ , សាលាចំណាយថ្លៃជាង ចំនួន520$ និងសហាគមន៍ចេញខ្សាច់ ថ្ម។



Picture 19: ការជួសជុលសាលា

▪ សាលាបឋមសិក្សាអូរទទួលបានសម្ភារៈធ្វើសួនកុមារ ដើម្បីកែលម្អបរិស្ថានសាលារៀន និងធ្វើជំរាល បង្កាន់ដៃសម្រាប់កុមារពិការ។

▪ សាលាបឋមសិក្សាទន្លាប់ទទួលបានសម្ភារៈជួសជុលថ្នាក់រៀន ២បន្ទប់ ដែលខាងNTFP ចំណាយលើកសម្ភារៈអស់ចំនួន575 $, ខាងសហាគមន៍ចេញចេញខ្សាច់ថ្ម និងកម្លាំងពលកម្ម និងខាងសាលាចេញសម្ភារៈដែលខ្វះខាត

ក្នុងការជួសជុលសាលា និងគាំទ្រសម្ភារៈធ្វើជំរាល និងបង្កាន់ដៃសម្រាប់កុមារពិការ

▪ សាលាបឋមសិក្សាឬស្សីស្រុកទទួលបានសម្ភារៈសាងសង់សាលាមត្តេយ្យ ចំនួន១ខ្នង ១បន្ទប់ ។ NTFP ចំណាយអស់ចំនួន3134 $, ខាងសាលាចំណាយអស់125$ និងសហគមន៍ចេញខ្សាច់ចំនួន ១០គីប, ថ្មចំនួន១០គីប, ឈើចំនួន៣គីប និងកម្លាំងពលកម្មចំនួន៣៥នាក់ និងគាំទ្រសម្ភារៈសាងសង់រោងដាំបាយសម្រាប់អាហារកុមារពេលព្រឹក ។ NTFPចំណាយអស់ចំនួន100 $, សាលាចេញសម្ភារៈដែលខ្វះខាតក្នុងការសាងសង់រោងដាំបាយ និងសហគមន៍ចេញជាឈើ។


Picture 20: សកម្មភាពសួនបំណិនរបស់កុមារ

**Act.3.1.11: ការគាំទ្រសួនបំណិនជីវិតក្នុងសាលា**

គាំទ្រសម្ភារៈធ្វើសួនបំណិនជីវិត ដល់សាលាបឋមសិក្សាឬស្សីស្រុក (សួនមានទំហំ ២០០$m^2$)។ NTFP ចំណាយអស់138$ ខាងសាលានិងសហគមន៍ចេញកម្លាំងពលកម្ម

**Act 3.1.12: ការបច្ចុបន្នភាព និងថតរូបកុមារ**

ចុះធ្វើបច្ចុប្បន្នភាពនិងថតរូបកុមារតំណាងសហគមន៍នៅភូមិព្រាល បានចំនួន៦០នាក់ ស្រី ៣១នាក់។ លទ្ធផល បានធ្វើកិច្ចព្រមព្រៀងជាមួយអាណាព្យាបាលកុមារដើម្បីសុំការអនុញ្ញាត និងការយល់ព្រមបន្តឲ្យកុមារចូលរួមជាមួយគម្រោង ថតរូបកុមារ និងបានសម្ភាសន៍កុមារ។

**សកម្មភាពក្រុមយុវជនចុះចែកអាល់កុល**

គាំទ្រយុវជនចុះចែកអាល់កុលដល់ក្រុមគោលដៅ(ក្រុមកសិករ, ក្រុមយុវជន, ក្រុមSSC និងក្រុមSC) ទាំង៨ភូមិ រួមមានៈ

- ភូមិព្រាល បានចែកចំនួន៣១នាក់ ស្រី១៨នាក់
- ភូមិសន្លុងជ័យ បានចែកចំនួន២៨នាក់ ស្រី១៨នាក់
- ភូមិទន្លាប់ បានចែកចំនួន ៦១នាក់ ស្រី៣៥នាក់




- ភូមិឬស្សីស្រុក បានចែកចំនួន ៥៧នាក់ ស្រី៣៦នាក់
- ភូមិបឹង បានចែកចំនួន២៩នាក់ ស្រី១៨នាក់
- ភូមិអូរ បានចែកចំនួន៣៧នាក់ ស្រី២៩នាក់
- ភូមិជោគជ័យ បានចែកចំនួន១៣នាក់ ស្រី៧នាក់
- ភូមិសំបូរ បានចែកចំនួន៣០នាក់ ស្រី២៣នាក់។

## ២.២.កម្មវិធីលើកស្ទួយ និងពង្រឹងសហគមន៍ (CEA)

## ២.២.១ លទ្ធផលសម្រេចបានពីគម្រោងការលើកកំពស់សិទ្ធិសហគមន៍ជនជាតិដើមភាគតិច ខេត្តព្រះវិហារ



Picture 21: ផ្តល់វគ្គបណ្តុះបណ្តាលដល់អាជ្ញាធរពី EIA

▪ អជ្ញាធរ ចំនួន ២៥ នាក់ ស្រី ចំនួន ៤ នាក់ (មេភូមិ ក្រុមប្រឹក្សាឃុំ) នៅឃុំពុទ្រា ឃុំស្អាង និងតស៊ូ ទទួលបានវគ្គបណ្តុះបណ្តាលពីការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និងសង្គមដែលសម្របសម្រួលដោយមន្ទីរបរិស្ថាន មានរយៈពេល ២ ថ្ងៃ។ លទ្ធផលមុននិងក្រោយវគ្គបណ្តុះបណ្តាលៈ មុនវគ្គល្អមាន ៣០ % មធ្យម និងខ្សោយ ៧០ % នៃអ្នកចូលរួម។ ក្រោយវគ្គ ល្អ ៩៣ % និងខ្សោយ ៧ %។



Picture 22: ផ្តល់វគ្គបណ្តុះបណ្តាលដល់ជនបង្គោលពីជំនាញសម្របសម្រួល FPIC

▪ ជនបង្គោលចំនួន ៣៧ នាក់ ស្រីចំនួន ២១ នាក់ ទទួលបានវគ្គបណ្តុះបណ្តាលពីប្រធានបទជំនាញសម្របសម្រួល ជំនាញទំនាក់ទំនង ច្បាប់ភូមិបាល ការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និងសង្គម និងគោលការណ៍ (FPIC) ដែលបានសម្របសម្រួលដោយបុគ្គលិក អង្គការអនុផលព្រៃឈើមានរយៈពេល៣ថ្ងៃ។លទ្ធផលមុននិងក្រោយវគ្គ បណ្តុះបណ្តាល បានបង្ហាញអោយឃើញថាៈ មុនវគ្គល្អមាន ៥ % មធ្យម ៦ % និងខ្សោយ ៨៩ % នៃអ្នកចូលរួម។ក្រោយវគ្គល្អ៧៤ %មធ្យម ២៤ %និង ខ្សោយ២ %។



Picture 23: ជនបង្គោល និងបុគ្គលិក ទទួលបានវគ្គបណ្តុះបណ្តាលពីរបៀបប្រើ(PHs & SOEK)

▪ ជនបង្គោលចំនួន ១៣ នាក់ និងបុគ្គលិកចំនួន ៦ នាក់ (សរុប ១៩ នាក់ ស្រី ចំនួន ៦ នាក់) ទទួលបាន វគ្គបណ្តុះបណ្តាល ពីរបៀប ប្រើឧបករណ៍វាស់ជាតិពុលក្នុងទឹក (PHs & SOEK) សម្របសម្រួលដោយមន្ត្រីកសិកម្មស្រុក មានរយៈពេល ២ ថ្ងៃ។ តាមការអង្កេតពេលរៀន និងអនុវត្ត ឃើញថា៧៥ % នៃអ្នកចូលរួមមានការយល់ដឹងបានល្អ និង ២៥ % មធ្យម។



Picture 24: ផ្តល់វគ្គបណ្តុះបណ្តាលពីរបៀបប្រើ Online ដល់សិស្សអនុវិទ្យាល័យ

▪ អង្គការអនុផលព្រៃឈើបានសហការជាមួយលោកនាយក លោកគ្រូអ្នកគ្រូក្នុង អនុវិទ្យាល័យចំនួន ៤ មាន អនុវិទ្យាល័យ ត្រពាំងទន្ទឹមថ្មល់កោងរស្មីរីករាយនិង រូសរាន់ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់កូនសិស្ស

ពីរបៀបប្រើប្រាស់បច្ចេកវិទ្យាតាមប្រព័ន្ធ Online ( Google Meet & Messenger Room) មានកូនសិស្ស ចូលរួមសរុប ២៩ នាក់ ស្រី ចំនួន ១៥ នាក់។ យោងតាមលទ្ធផល មុន និងក្រោយវគ្គឃើញថា៖ មុនវគ្គ ០ % មានការយល់ដឹងបានល្អ ៤០ % មធ្យម និង ៦០ % ខ្សោយ។ ក្រោយវគ្គ៖ ៧៣ % មានការ យល់ដឹងបានល្អ ២០% ទទួលបាន មធ្យម និង ៧ % ខ្សោយ។

▪ អង្គការអនុផលព្រៃឈើបានសហការជាមួយលោកនាយក លោកគ្រូអ្នកគ្រូក្នុងអនុវិទ្យាល័យចំនួន ៤ មានអនុវិទ្យាល័យត្រពាំងទន្ទឹម ថ្នល់កោង រស្មី រីករាយ និងរួសរាន់ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់លោកគ្រូអ្នកគ្រូពីរបៀបប្រើប្រាស់បច្ចេកវិទ្យាតាមប្រព័ន្ធ Online ( Google Meet & Messenger Room) មានលោកគ្រូ អ្នកគ្រូចូលរួមសរុប ១៦ នាក់ ស្រី ចំនួន ៨ នាក់។ យោងតាមលទ្ធផលមុន និងក្រោយវគ្គឃើញថា៖ មុនវគ្គ ១៨ % មានការយល់ដឹងបានល្អ ៣២ % មធ្យម និង ៥០ % ខ្សោយ។ ក្រោយវគ្គ៖ ៨៧ % មានការ យល់ដឹងបានល្អ ១៣% ទទួលបាន មធ្យម និង ០ % ខ្សោយ។



Picture 25: ផ្តល់វគ្គបណ្តុះបណ្តាលពីរបៀបប្រើ Online ដល់លោកគ្រូ អ្នកគ្រូ

▪ សហគមន៍ចំនួន ១៨៣៧ នាក់ ស្រីចំនួន ១១១៨ នាក់ នៅក្នុងតំបន់គោលដៅ (ក្នុងស្រុកជ័យសែន ចំនួន ៦ ឃុំ) បានចូលរួមការផ្សព្វផ្សាយពីការប្រើសារៈធាតុគីមីក្នុងវិស័យកសិកម្ម និងធ្វើរ៉ែមាស។ តាមការសួរសំណួរ មុននិងក្រោយ វគ្គឃើញថា ៦២ %នៃអ្នកចូលរួមមានការយល់ដឹងបានល្អ។



Picture 26:ការផ្សព្វផ្សាយជាមួយសហគមន៍

▪ កូនសិស្សអនុវិទ្យាល័យចំនួន ៤៤៨ នាក់ ស្រី ២២០ នាក់ (នៅស្រុករវៀងមាន ៤ អនុវិទ្យាល័យ៖ អនុវិទ្យាល័យត្រពាំងទន្ទឹម ថ្នល់កោង រស្មី រីករាយ និងរួសរាន់ ស្រុកជ័យសែន មាន៤ គឺអនុវិទ្យាល័យ បដិវឌ្ឍន៍ ផ្កា និងខ្យង នៅស្រុកឆែបមាន ២ អនុវិទ្យល័យគឺ ឆែបមួយ និងសំបូរ)បានចូលរួមការផ្សព្វផ្សាយ ពីការប្រើសារៈធាតុ គីមីក្នុង វិស័យកសិកម្ម និងធ្វើរ៉ែមាស។ តាមការសួរសំណួរមុននិងក្រោយវគ្គឃើញថា ៧០ %នៃអ្នក ចូលរួមមានការយល់ដឹងបានល្អ។



Picture 27: ការផ្សព្វផ្សាយជាមួយកូនសិស្ស



Picture 28: ការធ្វើវេទិការជាមួយសហគមន៍

▪ អង្គការអនុផលព្រៃឈើបានសហការជាមួយអាជ្ញាធរភូមិ ឃុំ ស្រុក បានរៀបចំធ្វើវេទិការពិគ្រោះ យោបល់ជាមួយអ្នក ពាក់ព័ន្ធ រួមមានអាជ្ញាធរភូមិ ឃុំ ស្រុក មន្ត្រីកសិកកម្មស្រុក និងមណ្ឌលសុខភាពស្តីពីការប្រើប្រាស់សារធាតុគីមីក្នុងវិស័យកសិកម្ម និងអាជីវកម្មរ៉ែ នៅក្នុងឃុំរូសរាន់ រីករាយ រំដោះ និងរមទម មានអ្នកចូលរួមសរុប ២៧១ នាក់ ស្រី ១៣៦ នាក់។ ជាលទ្ធផល ៦៨ % នៃអ្នកចូល រួមមានការយល់ដឹងពីផលប៉ះពាល់ និងពីរបៀបការពារ។

▪ ៦១ % នៃជនបង្គោលចំនួន ៣៩ នាក់ មានចំណេះដឹង និងជំនាញអាចសម្របសម្រួលការប្រជុំ និងផ្សព្វផ្សាយជាមួយសហគមន៍បាន។

▪ ១០ % នៃសហគមន៍ ចំនួន ១៨៣៧ នាក់មានការយល់ដឹង និងមានទំនុកចិត្ត អាច ចែក រំលែកទៅដល់សហគមន៍បាន។

▪ អង្គការអនុផលព្រៃឈើបានទិញ ឧបករណ៍ (SOEK) ចំនួន ១ សម្រាប់ពិនិត្យជាតិពុលនៅក្នុងទឹក និងទិញឧបករណ៍ (Nitrate Food Tester) ចំនួន ១ សម្រាប់ត្រួតពិនិត្យជាតិពុលក្នុងទឹក និងម្ហូបអាហារ។

## ២.២.២ លទ្ធផលសំខាន់ៗរបស់គម្រោង"ជំនាន់ថ្មី" (New Generation)

**លទ្ធផលទី១៖ កុមារី និងស្ត្រីវ័យក្មេង រួមជាមួយនឹងក្មេងប្រុស និងបុរសវ័យក្មេង គឺជាភ្នាក់ងារសកម្មនៃការផ្លាស់ប្តូរក្នុងការលើកកម្ពស់ការការពារកុមារ និងសិទ្ធិសុខភាពបន្តពូច និងសមភាពយេនឌ័រនៅក្នុងសហគមន៍របស់ពួកគេ។**

គម្រោង ជំនាន់ថ្មី បានបើកវគ្គបណ្តុះបណ្តាលដល់ 185 (F:44, M:29 អាយុ 18-24, G:54, B:37 អាយុ 15-17, G:16, B:5 អាយុ 10-14) ដែលជាតំណាងរបស់កុមារ ក្លឹប និងក្រុមគាំទ្រកុមារ ក្រោម ប្រធានបទការសម្របសម្រួល ការសរសេររបាយការណ៍ ការផ្លាស់ប្តូរយេនឌ័រនិងសមភាពយេន ឌ័រ វិធីសាស្ត្រតស៊ូមតិ ផលប៉ះពាល់បរិស្ថានពីការប្រែប្រួលអាកាសធាតុ។ ផ្អែកលើការធ្វើតេស្ត ក្រោយបញ្ចប់វគ្គបានបង្ហាញថា 16% (29នាក់/11 ស្រី)បានយល់ដឹងច្បាស់ ពីប្រធានបទដែល បានបណ្តុះបណ្តាលខាងលើ ហើយពួកគេអាចជួយដល់សកម្មភាពរបស់ក្លឹបកុមារដូចជាការប្រជុំក្លឹបកុមារ ការដឹកនាំការសំដែងរឿង ការអប់រំមិត្តភ័ក្តិ ការស្រាវជ្រាវ និងការតស៊ូមតិ។

គម្រោង នេះគ្រោងនឹងបន្តកសាងសមត្ថភាពដល់ ៨៥% នៃអ្នកតំណាងកុមារ និងក្រុមគាំទ្រកុមារ ចំនួន ១៨៥ នាក់ តាមរយៈការបង្វឹក។

គម្រោងបានផ្តល់វគ្គកសាងសមត្ថភាពដល់ 179 (F:47, M:28 អាយុ 18-24, G:57, B:28 អាយុ 15-17, G:12, B:7 អាយុ 10-14) ដែលជាសមាជិកក្លឹបកុមារ និង ក្រុមគាំទ្រកុមារ ពីប្រធានបទ អំពើហិង្សាផ្អែកលើយេនឌ័រ និងភាពជាបុរស អំពើហិង្សាផ្អែកលើយេនឌ័រ បម្រែបម្រួលអាកាសធាតុ (ផលប៉ះពាល់នៃគ្រោះរាំងស្ងួត និងទឹកជំនន់) អំពើហិង្សាផ្អែក លើយេនឌ័រ ប្រឆាំងនឹង ស្ត្រី និងក្មេងស្រី និងផែនការ។ ផ្អែកលើការធ្វើតេស្តក្រោយវគ្គបានបង្ហាញថា 38% (68/20 ស្រី)បានយល់ដឹងច្បាស់ពី ប្រធានបទខាងលើ។ គម្រោងបានគ្រោងនឹងបន្ត កសាងសមត្ថភាពដល់ 62% នៃ 179 នាក់។

ក្លឹបកុមារបានរៀបចំការប្រជុំប្រចាំខែរបស់ពួកគេចំនួន 24 ដងជាមួយនឹងអ្នកចូលរួម 483 (F:25 ដែលមានអាយុ 25+, F:115, M:88 អាយុ 18-24, G:134,B:83 អាយុ 15-17, G:35 B:27 អាយុ 10-14) នៅឃុំចំនួន 13 ដែលមានរបៀបវារៈដូចខាងក្រោម 1.Achievements, 2.4 package of Child Rights and Child Protection (ទម្រង់អំពើហឹង្សា) 3.Gender transformative 4.Gender base violence (Girl and boyhood) , 5. លើកបញ្ហានិងដំណោះស្រាយ 6. ដើម្បីបង្កើតផែនការ។ លទ្ធផលនៃការប្រជុំឆ្លុះបញ្ចាំងបានរកឃើញថាពាក់កណ្តាលនៃអ្នកចូលរួមបានរៀន និងដឹងពីរបៀបវារៈខាងលើ។

សមាជិកក្លឹបចំនួន 47 នាក់ (F:21, M:15 ជាមួយអាយុ 18-24, G: 7, B: 4 ជាមួយអាយុ 15-17) បានធ្វើមិត្តអប់រំមិត្តចំនួន12លើក ពីផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍វ័យកុមារ ការការពារកុមារ សមភាពយេនឌ័រដល់ កុមារនិងយុវជនក្នុងសហគមន៍ចំនួន 284 (F:48, M:30, G:91, B:79) ។

ក្លឹបកុមារចំនួន 48 នាក់ (F:13, M:5 អាយុ 18-24, G:19, B:9 អាយុ 15-17, G:2 អាយុ 10-14) បានធ្វើការសំដែងរឿងចំនួន 3 ដងលើប្រធានបទនៃផលប៉ះពាល់អវិជ្ជមានពីការបាត់បង់ការអប់រំ និងផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍វ័យកុមារមានអ្នកចូលរួមទស្សនាចំនួន 141 (F:35, M:24, G:49, B:33)។

ក្លឹបកុមារចំនួន31នាក់ (F:12,M:5 អាយុ 18-24,G:6, B:7 ជាមួយអាយុ 15-17, G:1 ជាមួយអាយុ 10-14) បានធ្វើការស្រាវជ្រាវចំនួន 3 នៅឃុំ Malik និង Kechong លើផលប៉ះពាល់អវិជ្ជមានពីកុមារពីការបោះបង់ការសិក្សា និងការរំលោភសិទ្ធិកុមារ។

ការស្រាវជ្រាវសកម្មភាពត្រូវបានសម្ភាសន៍ជាមួយអ្នកចូលរួមចំនួន 128 នាក់ ស្រី 64 នាក់ ដែលជាកុមារ យុវជន ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ និងអាជ្ញាធរភូមិ ឃុំ ហើយពួកគេបានរាយការណ៍ថា មនុស្ស 70 នាក់ ស្រី 25 នាក់ត្រូវបានបោះបង់ចោលការសិក្សាពីថ្នាក់ទី 6-9 ដែលមានអាយុ 14-24 ឆ្នាំ។ មនុស្សទាំងនោះប្រឈមមុខនឹងការប្រើប្រាស់គ្រឿងញៀន ក្លាយជាក្មេងទំនើង អសមត្ថភាពក្នុងការស្វែងរកការងារធ្វើ រៀបការវ័យកុមារ។ និងកុមារចំនួន

០៣នាក់ ស្រី ២នាក់ អាយុពី ១២-១៦ឆ្នាំ ប្រឈមនិងរណើរំលោភបំពានពីឪពុកម្តាយ។ កុមាររងគ្រោះទាំងនោះ ប្រឈមមុខនឹងការរំលោភលើរាងកាយកុមារ៣នាក់បោះបង់ការសិក្សា។ ក្រុមស្រាវជ្រាវនាំយកបញ្ហាទាំងនោះមកពិភាក្សាជាមួយសមាជិក ក្លឹបកុមារ ដើម្បីរាយការណ៍ នៅក្នុងកិច្ចប្រជុំ CCWCs ។

**លទ្ធផលទី២៖ ក្រុមគ្រួសារ សមាជិកសហគមន៍ និងអ្នកដឹកនាំមូលដ្ឋានទទួលយក និងបំពេញនូវទំនួលខុសត្រូវរបស់ពួកគេ ដើម្បីធានាថា ក្មេងស្រី យុវនារី ក្មេងប្រុស និងបុរសវ័យក្មេង មានសិទ្ធិទទួលបានការការពារ និង សិទ្ធិសុខភាពបន្តពូជ។**

គម្រោង NewGen បានផ្តល់ការកសាងសមត្ថភាពដល់អ្នកចូលរួមចំនួន 196 នាក់ (F:41, M:114 aged 25+, F:19, M:20 aged 18-24, G:1 aged 17) ដែលជា VCBCPMs ស្តីពីសិទ្ធិកុមារ ការការពារកុមារ ប្រភេទនៃសេវាសង្គម កាតព្វកិច្ចរបស់ឪពុកម្តាយ ភារៈកិច្ចរបស់កុមារ ការអប់រំបែបវិជ្ជមាន និងសមភាពយេនឌ័រ។ ការធ្វើតេស្តក្រោយវគ្គបានបង្ហាញថា 18% (ស្ត្រី 32/7 នាក់) បានយល់ដឹងច្បាស់ពីប្រធាន បទខាងលើ ពួកគេអាចអនុវត្តចំណេះដឹង របស់ពួកគេទាក់ទង នឹងការលើកកម្ពស់សិទ្ធិកុមារ និងសិទ្ធិសុខភាពផ្លូវភេទ តាមរយៈកិច្ចប្រជុំភូមិចំនួន 78 ដល់អ្នកចូលរួម 887 (F:271), M:459 អាយុ 25+, F:70, M:47 អាយុ 18-24,G:25, B:15 អាយុ 15-17)។

គម្រោង NewGen បានផ្តល់វគ្គបណ្តុះបណ្តាលចំនួន 4 ដល់ 63 (F:23, M:40) ដែលជាតំណាង CCWCs នៃឃុំគោលដៅចំនួន 13 ស្តីពីការការពារកុមារ សិទ្ធិសុខភាពបន្តពូជ ជំនាញសម្របសម្រួល សមភាពយេនឌ័រ និងតួនាទីរបស់ឪពុកម្តាយ។ ការធ្វើតេស្តក្រោយវគ្គ បានបង្ហាញថា47% (ស្ត្រី 29/11 នាក់) បានយល់ដឹងច្បាស់ពីប្រធានបទដែលបានបណ្តុះបណ្តាលខាងលើ។ CCWC ចំនួន ១១ នាក់ ស្រី ៦ នាក់ បានផ្តល់អនុសាសន៍ដល់អ្នកចូលរួមចំនួន ២៥៦ នាក់ (F:139, M:96, G:19, B:2) អំពីទម្រង់អំពើហឹង្សាទាំង 4 (ការរំលោភបំពានផ្លូវភេទ រំលោភលើរាងកាយនិងមិនអើពើ) កញ្ចប់សិទ្ធិកុមារទាំង៤ (សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការ ការពារសិទ្ធិ។

ក្រុមឪពុកម្តាយចំនួន១៣ក្រុម បានធ្វើការប្រជុំចំនួន ២០លើក ដែលមានអ្នកចូលរួម ៣០៤នាក់(F:160, M:112 អាយុ 25+, F:24, M:8 អាយុ 18-24 ឆ្នាំ) លើតួនាទីរបស់ក្រុមមាតាបិតា អាកប្បកិរិយាវិជ្ជមាន លើកបញ្ហាតាមភូមិ បង្កើតផែន។

78 គណៈកម្មការកិច្ចការពារកុមារថ្នាក់ភូមិបានរៀបចំប្រជុំចំនួន៧៨លើក ដែលមានអ្នកចូលរួម 887នាក់(F: 271, M:459 អាយុ 25+, F:70, M: 47 អាយុ 18-24, G:25, B:15 អាយុ 15-17)។ របៀបវារៈនៃកិច្ចប្រជុំគឺ៖

1.ជំនាញក្រុមឈានមុខ (កិច្ចប្រជុំ ការសន្ទនា)

2.តួនាទី និងទំនួលខុសត្រូវ
3.ផែនការសកម្មភាពប្រចាំឆ្នាំ
4.ជំនាញលើការរាយការណ៍ និងយន្តការបញ្ជូនបន្ត ជាមួយនឹងការឆ្លើយតបនឹងយេនឌ័រ និងធនធាន។
លទ្ធផលឆ្លុះបញ្ចាំងជាមួយនឹងពាក់កណ្ដាលនៃ 495 យល់ដឹងអំពីៈ
1.ជំនាញសំរបសំរួល (កិច្ចប្រជុំ ផ្សព្វផ្សាយ)
2. តួនាទី និងការទទួលខុសត្រូវ
3. ផែនការសកម្មភាពប្រចាំឆ្នាំ
4. យន្តការរាយការណ៍ និងបញ្ជូនបន្ត នឹងការឆ្លើយតបនឹងបញ្ហាយេនឌ័រ។

**លទ្ធផលទី៣ៈ រដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងតួអង្គសង្គមស៊ីវិលក្នុងតំបន់ ផ្ដល់សេវាកម្ម និងការគាំទ្រប្រកបដោយគុណភាព និងសមធម៌ដល់កុមារ និងយុវជនដែលងាយរងគ្រោះ ជាពិសេសកុមារី និងស្ត្រីវ័យក្មេង។**

គម្រោង បានផ្ដល់ការបណ្ដុះបណ្ដាលរយៈដល់ប៉ូលីសចំនួន 17 នាក់ ស្ត្រី 4 នាក់ ដែលមកពី 4 ស្រុក និង 13 ឃុំ នៅក្នុងតំបន់គម្រោង។ ស្ដីពីអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ (UNCRC) អំពើហិង្សាផ្អែកលើយេនឌ័រ បច្ចេកទេសអន្តរាគមន៍ ការបញ្ជូនករណីកុមារ , ច្បាប់ទាក់ទងនឹងការការពារកុមារ។ វគ្គបណ្ដុះបណ្ដាលនេះមានគោលបំណងពង្រឹងប៉ូលីសបំពេញតួនាទីឆ្លើយតបករណីរំលោភលើកុមារ និងយុវជនតាមរយៈការរាយការណ៍ពីក្លឹបកុមារ VCBCPMs និងក្រុមឪពុកម្ដាយ។ ការធ្វើតេស្តក្រោយវគ្គបានបង្ហាញថា 60% (10/2 ស្រី) បានយល់ដឹងច្បាស់ពីប្រធាន បទខាងលើ និង អនុវត្តតួនាទី របស់ពួកគេក្នុងការឆ្លើយតបលើបញ្ហាកុមារនិងយុវជន ដូចជាៈ
១.កុមារចំនួន២៦នាក់ អាយុ១៤ដល់១៧ឆ្នាំបានប្រើប្រាស់គ្រឿងញៀន និងត្រូវបានឃាត់ខ្លួនចំនួន១៤នាក់ ព្រមទាំងធ្វើកិច្ចសន្យាជាលាយលក្ខអក្សរ។
២.នគរបាលប៉ុស្តិ៍ និងនគរបាលស្រុក បានចាប់ខ្លួនជនដៃដល់ដែលរួមភេទក្មេងស្រី២នាក់ អាយុ១១ឆ្នាំ និង១៣ឆ្នាំ និងជនបង្ក២នាក់បញ្ជូនទៅតុលាការខេត្តរតនគិរី។

គម្រោងបានសម្របសម្រួល កិច្ចប្រជុំមួយ PWCC, DWCCs, CWCCs ដែលអ្នកចូលរួម 20 នាក់ ស្រី 14 នាក់ ។ កិច្ចប្រជុំនេះមានគោលបំណងពង្រឹងសមត្ថភាព និងចំណេះដឹងពី
- សិទ្ធិកុមារមាន ៥៤ មាត្រា។
-ក្រមសីលធម៌សីលធម៌កុមារ។
- តួនាទីរបស់ CWCCs (Brakas3840) ។

- បណ្តាញការពារគ្រួសារ។
- យេនឌ័រ និងអំពើហិង្សាមូលដ្ឋានយេនឌ័រ។
- បង្កើតផែនការរបស់ PWCC, DWCC និង CWCC ដើម្បីលើកកម្ពស់ការការពារកុមារ។
ផ្អែកលើកិច្ចប្រជុំឆ្លុះបញ្ចាំង ដើម្បីធានាបាននូវការសិក្សារបស់ពួកគេពីកិច្ចប្រជុំ បានរកឃើញថា ពួកគេភាគច្រើនបានយល់អំពីផែនការប្រចាំឆ្នាំសហគមន៍ និងតួនាទីរបស់ CBCPMs ពីឃុំ-ខេត្ត ទាក់ទងនឹងការការពារ និងការរំលោភលើការការពារកុមារ។
គ.ក.ន.ក ឃុំ បានរៀបចំការប្រជុំចំនួន 16លើក ដែលមានអ្នកចូលរួម162 នាក់(F:20, M:118 aged 25+, F:15, M:4 aged 18-24, G:3, B:2 aged 15-17)។
បានបង្កើតផែនទីសង្គមសេវាសម្រាប់ឃុំឆ្នាំ២០២២ ដែលផ្អែកលើសូចនាករទាំង ១៤។
កិច្ចប្រជុំចំនួន 2 នៅស្រុកតាវែង និងស្រុកវើនសៃ ដែលមានអ្នកចូលរួមចំនួន 35 នាក់ (F:13, M:8 aged 25+, F:8, M:4 aged 18-24, G:2 age 17)។ កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាអំពីការឆ្លើយតបយេនឌ័រពីក្នុងការគាំទ្រសេវា ពីគណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារថ្នាក់ឃុំ ស្រុក និងខេត្ត។
របៀបវារៈ

1. គោលបំណងរបស់អ្នកផ្តល់សេវាលើការឆ្លើយតបយេនឌ័រ
2. ប្រភេទនៃសេវាសង្គមពីឃុំ និងស្រុក
3. បង្កើតគោលការណ៍ណែនាំដំណើរការបញ្ជូនផ្អែកតាមអាយុ (1. ការបញ្ជូនបន្តដោយអាយុ <18, បញ្ជូនបន្តអាយុ >18)
4. ពិនិត្យយន្តការរបាយការណ៍ឆ្លើយតបយេនឌ័រ ( ទម្រង់បែបបទពេញលេញនៃករណីអ្នកផ្តល់សេវាអាសយដ្ឋាន)។

ឃុំចំនួន 5 បានឯកភាព និងអនុវត្តតាមដំណើរការបញ្ជូនបន្តជាពីប្រភេទគឺអាយុតិចជា 18 ឆ្នាំ និងអាយុលើស 18 ឆ្នាំ។

## ២.៣.កម្មវិធីអភិវឌ្ឍសហគមន៍និងការអប់រំ (CDE)

## ២.៣.១ លទ្ធផលសំខាន់ៗ របស់គម្រោងអក្ខរកម្ម (NFE)

ផ្តល់ការអប់រំពីរភាសាក្នុងខេត្តរតនគីរី

- គ្រូអក្ខរកម្មសរុបចំនួន៣៦នាក់ ស្រី១៥នាក់ និងគ្រូបង្គោលជាបុរសចំនួន៦នាក់ ត្រូវបានទទួលវគ្គបណ្តុះបណ្តាលពីវិធីសាស្រ្តបង្រៀនចំនួន៩វគ្គ។ នៅក្នុងចំណោមអ្នកចូលរៀនទាំងអស់គឺមានអ្នកខ្លះបានចូលរៀនចំនួន៣វគ្គ និងអ្នកខ្លះទៀតចូលបាន ចំនួន ១វគ្គ។ វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដោយប្រើប្រាស់ជាភាសាកាវែត និង

ភាសាខ្មែរសម្រាប់ការបណ្តុះបណ្តាល។គ្រូអក្ខរកម្មចំនួន៣៦នាក់បានយកជំនាញពីវិធីសាស្រ្តបង្រៀន យកទៅបន្តបង្រៀនបន្តនៅថ្នាក់រៀងៗខ្លួនបានល្អប្រសើរ។

- ថ្នាក់សរុបចំនួន២៣ថ្នាក់ត្រូវបានតាមដានការបង្រៀនចំនួន១៦ដង ហើយក្នុងការ តាមដាននោះគឺមាន ថ្នាក់ចំនួន១មិនត្រូវបានដំណើរការបង្រៀនទេ ព្រោះគ្រូនិងសិស្សបានធ្វើការផ្លាស់ប្តូរ ទៅធ្វើចំការថ្មីផ្សេងទៀត។
- គម្រោងបានឧបត្ថម្ភសូឡាសរុបចំនួន៨ផ្ទាំង ដែលបានដាក់អោយប្រើប្រាស់តាមថ្នាក់រៀននិងមណ្ឌលបណ្តុះបណ្តាលសូឡាទាំងអស់នោះត្រូវបានដាក់ប្រើប្រាស់សម្រាប់គាំទ្រការបង្រៀននៅពេលយប់ និងការបង្រៀនកុំព្យូទ័រ។
- សិស្សកុំព្យូទ័រចំនួន២៩នាក់ ស្រី១៩នាក់ ត្រូវបានរៀបចំវគ្គរដ្ឋបាល (Microsoft Word) ហើយបច្ចុប្បន្នពួកគេទាំងនោះត្រូវបានចេះប្រើប្រាស់ តែនៅមិនទាន់ចេះប្រើប្រាស់បាន១០០%នៅឡើយទេ។
- សិស្សសរុបចំនួន៣៣៥នាក់ស្រី១៧៦ ដែលជាសិស្សអក្ខកម្មថ្នាក់កាវែត និងថ្នាក់ខ្មែរត្រូវបាន ចុះឈ្មោះចូលរៀនដើមឆ្នាំ២០២១ហើយនៅចុងឆ្នាំ២០២១ គឺមានសិស្សបោះបង់ចំនួន២០នាក់ ក្នុងនោះមានស្រីចំនួន១៤ផងដែរ។
- នៅក្នុងឆ្នាំ២០២១ផងដែរមានថ្នាក់ចំនួន៩ត្រូវបានរៀនចប់កម្មវិធីអក្ខកម្មរយៈពេល៣ឆ្នាំផងដែរ។ហើយថ្នាក់ដែលនៅសល់នឹងបញ្ចប់នៅចុងឆ្នាំ២០២១។
- សិស្សអក្ខរកម្មចំនួន១៦៨នាក់ ស្រី ៨៦នាក់ត្រូវបានរៀបចប់កម្មវិធីអក្ខរកម្មចំនួន៣ឆ្នាំ ហើយក្នុងនោះ មានសិស្សចំនួន១៦០នាក់ ស្រី៨២នាក់ បានបន្តរៀនទៅថ្នាក់រដ្ឋផងដែរ។
- មជ្ឈមណ្ឌលធំចំនួន២ត្រូវបានសាងសង់សម្រាប់ក្មេងៗចូលអានសៀវភៅនិងរៀនកុំព្យូទ័រ។និងមានមណ្ឌលចល័តចំនួន២ផ្សេងទៀតត្រូវបានសាងសង់ផងដែរសម្រាប់ក្មេងៗនៅតាមចម្ការស្រែបានទទួលការរៀនសូត្រផងដែរ។
- អក្ខរក្រមភាសាកាវែតចំនួន៥ត្រូវបានកែសម្រួលនិងទទួលបានការយល់ព្រមដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយក្រសួងអប់រំយុវជន និងកីឡា។

## ២.៣.២ លទ្ធផលសំខាន់ៗ របស់គម្រោងមជ្ឈមណ្ឌលសិក្សាសហគមន៍ចល័ត (MCLC)

**លទ្ធផលសម្រេចបានរបស់គម្រោងមជ្ឈមណ្ឌលសិក្សាសហគមន៍ចល័ត(MCLC)ក្នុងឆ្នាំ២០២១ មានដូចខាងក្រោម៖**

1. សាងសងមជ្ឈមណ្ឌលសិក្សាសហគមន៍ចល័តចំនួន៤កន្លែងនៅតាមក្រុមចំការ ។
2. គណៈកម្មការចំនួន១៣នាក់ស្រី៤នាក់ត្រូវបានបណ្តុះបណ្តាលពីការគ្រប់គ្រងបណ្ណាល័យចំនួន៣លើក។

3. គណៈកម្មការចំនួន១០នាក់ស្រី៥នាក់ត្រូវបានបណ្តុះបណ្តាលពីការសរសេររបាយការណ៍ និងកំណត់ហេតុចំណួន២លើក។
4. ប្រជុំត្រីមាសឆ្លុះបញ្ចាំងបីផែនការសកម្មភាព តួនាទី និងបញ្ហា គណៈកម្មការ ចំនួន១៣នាក់ស្រី៥នាក់ ។
5. ប្រជុំរៀងរាល់បីខែម្តងពង្រឹងពីវិធីសាស្រ្តការបង្រៀនរបស់គ្រូមានអ្នកចូលរួមចំនួន១០នាក់ស្រី៣នាក់។
6. គាំទ្រគណៈកម្មការផ្សព្វផ្សាយពីសិទ្ធិកុមារទាំង៤ សារៈសំខាន់ការរៀនសូត្រ អនាម័យបឋម ៣កុំ៣ការ ដោយមានអ្នកចូលរួមចំនួន៤៧០នាក់ស្រី២០១នាក់ ។
7. ប្រជុំរៀបចំមេរៀនជាមួយគណៈកម្មការដើម្បីចុះផ្សព្វផ្សាយដោយផ្អែកផែនការឆ្នាំ ដោយមានអ្នចូលរួមចំនួន១០នាក់ស្រី១នាក់។
8. ប្រជុំជាមួយគណៈកម្មការ និងអជ្ញាធរភូមិដើម្បីរៀបចំផែនការសកម្មភាពរបស់គណៈកម្មការអនុវត្តនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ចល័ត ។
9. ប្រជុំជ្រើសរើសទីកន្លែងសាងសង មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន២កន្លែងថ្មី នឹងគណៈកម្មការចំនួន៦នាក់ស្រី២នាក់ ជ្រើសរើសដោយអ្នកចូលរួមចំនួន១១៧នាក់ស្រី៥១នាក់
10. គាំទ្រសៀវភៅរឿងនិទាន ដល់មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន៥៤៨ក្បាល
11. ផ្តល់ទូក្នុង១កន្លែងចំនួន១ទាំងអស់៦កន្លែងសម្រាប់ដាក់សម្ភារៈ និងឧបករណ៍ ។
12. សិស្សចូលរៀនអក្ខរកម្មចំនួន១៤៨នាក់ស្រី៦៣នាក់ ។
13. កុមារ និងយុវជនខ្ចី និងអានសៀវភៅចំនួន១២៥២នាក់ស្រី៦១២នាក់។
14. កុមារ យុវជន និងមនុស្សពេញវ័យរៀនកំព្យូទ័ វគ្គ Typing និង Microsoft Word ចំនួន២៦នាក់ស្រី១១នាក់ ។

# III. របាយការណ៍សង្ខេបចំណូលចំណាយ

## របាយការណ៍ប្រាក់ចំណូល២០២១

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| ប្រាក់ដែលទទួលបានពីម្ចាស់ជំនួយនិងផ្សេងៗ | 2021 | 2020 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ICCO & Kerk in Actie ("ICCO") | 2,384 | 88,172 |
| New Life Literacy, Project Outreach and Prolieracy ("NLL") | 14,800 | 22,650 |
| DVV International (through Welthungerhlife) ("DVV") | 26,643 | 19,539 |
| Norwegian People's Aid Cambodia ("NPA") | 55,324 | 48,639 |
| Plan Cambodia -SIDA | - | 187 |
| Sternsinger International | 33,650 | 13,727 |
| Mission Alliance ("MA") | 157,356 | 140,193 |
| Child Right Coalition Cambodia ("CRC-Oxfarm") | 1,289 | 29,556 |
| Child's Dream ("CD") | 39,718 | 51,483 |
| Development and Partnership in Action ("DPA-Cord") | - | 20,250 |
| Plan International New Generation | 116,610 | 97,250 |
| Vicheasthan Bomreu Neak samrabsamroul Karngea akphiwat ("VBNK") | 3,106 | - |
| Other fund/returned ("CLOUDBURST") | 1,498 | - |
| Other income | 9,699 | 9,783 |
| **សរុបចំណូល** | **462,077** | **541,429** |



# <u>**របាយការណ៍ប្រាក់ចំណាយ២០២១**</u>

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| ចំណាយលើគម្រោងប្រតិបត្តិការ | 2021 | 2020 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ICCO & Kerk in Actie ("ICCO") | 2,385 | 54,222 |
| New Life Literacy, Project Outreach and Prolieracy ("NLL") | 16,890 | 17,241 |
| DVV International (through Welthungerhlife) ("DVV") | 24,417 | 19,866 |
| Norwegian People's Aid Cambodia (̏NPA̋) | 55,751 | 48,885 |
| Sternsinger International | 35,786 | 13,803 |
| Mission Alliance ("MA") | 156,897 | 147,529 |
| Child Right Coalition Cambodia ("CRC-Oxfarm") | (5) | 43,001 |
| Child's Dream ("CD") | 40,849 | 49,121 |
| Development and Partnership in Action ("DPA-Cord") | 4,151 | 14,025 |
| Plan International New Generation | 112,874 | 112,271 |
| Habitat | 1,152 | - |
| Vicheasthan Bomreu Neak samrabsamroul Karngea akphiwat ("VBNK") | 438 | - |
| Other fund/returned ("CLOUDBURST") | 1,498 | - |
| Other expenses (NTFP Funds) | 11,044 | 7,442 |
| **សរុបចំណាយ** | **464,127** | **527,405** |



## IV. សមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការNTFP

ក្នុងការលើកកំពស់ទៅលើអភិបាលកិច្ចល្អ និងការធ្វើអោយប្រសើរឡើងទៅលើការគ្រប់គ្រងនិងការចាត់ចែង នៅបច្ចុប្បន្ននេះ អង្គការអនុផលព្រៃឈើមានសមាជិកក្រុមប្រឹក្សាភិបាលចំនួន៥រូប:

- លោក ហួន ជុនឌី ប្រធានក្រុមប្រឹក្សាភិបាល
- លោក John Ashish សមាជិកក្រុមប្រឹក្សាភិបាល
- លោក រត្ន័ រម្យនា សមាជិកក្រុមប្រឹក្សាភិបាល
- លោកស្រី លៀង អ៊ី សមាជិកក្រុមប្រឹក្សាភិបាល
- លោក ភុំ ថុល សមាជិកក្រុមប្រឹក្សាភិបាល

រតនគិរី,ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០២២

រៀបចំដោយ

នាយកអង្គការអនុផលព្រៃឈើ(NTFP)

លោក ឡុង សេរី